**ឯកសារសង្ខេប**

គណៈកម្មការទី៥ ទទួលបន្ទុកកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ព្រឹទ្ធសភា

# ការទទួលបានយុត្តិធម៌នៅក្នុងប្រទេសនិយាយភាសាបារាំង

អ្នកស្រាវជ្រាវ៖ **នៅ សុជាតា**

ខែមិថុនា ឆ្នាំ២០១៤

**វិទ្យាស្ថានសភាកម្ពុជា**

ការទទួលបានយុត្តិធម៌គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិចម្បងផ្សេងៗទៀតដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗ និងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨។ សិទ្ធិនៃការទទួលបានយុត្តិធម៌នេះផ្តល់ការធានាដល់ពលរដ្ឋក្នុងការទទួលបាន ឬការការពារនូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ ការទទួលបានយុត្តិធម៌ផ្តោតទៅលើ៖ ដំណើរការឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ និងតម្លៃសេវាក្នុងការទទួលបានយុត្តិធម៌ដល់គូភាគី, ការប្រព្រឹត្តទៅលើជនរងគ្រោះ និងសាក្សី ភាពស្មើគ្នាចំពោះមុខច្បាប់ វិធានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចំណេះដឹងផ្នែកច្បាប់ និងការផ្សព្វផ្សាយច្បាប់។

របាយការណ៍សង្ខេបនេះនឹងបង្ហាញអំពី គោលការណ៍ចម្បងៗដែលបានកំណត់ដោយសភានៃប្រទេសនិយាយភាសាបារាំង(APF) ដើម្បីធានាការគោរពសិទ្ធិនេះពីសំណាក់ប្រទេសដែលជាសមាជិក។ អត្ថបទនេះក៏បានឆ្លុះបញ្ចាំងផងដែរ អំពីសិទ្ធិទទួលបានយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។

## I. គោលការណ៍នៃសិទ្ធិទទួលបានយុត្តិធម៌នៅក្នុងប្រទេសនិយាយភាសាបារាំង

បន្ទាប់ពីសន្និសីទរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកទី៣ នៃប្រទេសនិយាយភាសាបារាំងរួចមក[1] ដើម្បីធានាបាននូវសិទ្ធិទទួលបានយុត្តិធម៌ រដ្ឋជាសមាជិកនៃសភានេះត្រូវគោរពនូវគោលការណ៍ដូចជា៖

- ការទទួលបានយុត្តិធម៌ដែលមានឯករាជ្យភាព និងប្រសិទ្ធិភាព
- ការធានានូវនីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស
- យុត្តិធម៌ដែលជាចលករជម្រុញអោយមានការអភិវឌ្ឍន៍

ដើម្បីទទួលបាននូវយុត្តិធម៌ឯករាជ្យ៖

- សិទ្ធិនេះត្រូវតែបានធានាដោយរដ្ឋធម្មនុញ្ញ
- សភានៃរដ្ឋជាសមាជិកត្រូវមានតួនាទីអនុម័តច្បាប់ទាក់ទងនឹងលក្ខន្តិកៈរបស់ចៅក្រម
- ស្ថាប័នត្រួតពិនិត្យឯករាជ្យភាពរបស់ចៅក្រមត្រូវតែបង្កើត និង
- ការដាក់ទណ្ឌកម្មវិន័យត្រូវតែមាន តាមរយៈការបង្កើតច្បាប់ទាក់ទងនឹងការរៀបចំ និងដំណើរការនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម[2]។

រដ្ឋជាសមាជិកគួរមានគោលនយោបាយក្នុងការបង្កើតនូវកម្មវិធីជ្រើសរើស និងបណ្តុះបណ្តាល ដើម្បីពង្រឹងគុណភាព និងផ្តល់មធ្យោបាយសមស្របដល់បុគ្គលិកដែលបម្រើការនៅក្នុងវិស័យតុលាការដូចជា៖ ចៅក្រម ព្រះរាជអាជ្ញា មេធាវី សារការី អាជ្ញាសាលា ក្រឡាបញ្ជី និងប៉ូលីសយុត្តិធម៌។

---

[1] សន្និសីទលើកទី៣នៃរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌នៃប្រទេសនិយាយភាសាបារាំងរៀបចំឡើងដោយភ្នាក់ងារអន្តររដ្ឋាភិបាលនៃប្រទេសនិយាយភាសាបារាំង នៅទីក្រុង Caire នាខែវិច្ឆិកា ឆ្នាំ១៩៩៥។

[2] ដូចឯកសារយោងលើ ទំព័រទី៩។

បញ្ហាប្រឈមផ្សេងទៀតគឺកង្វះខាតប្រព័ន្ធចុះបញ្ជីសំណុំរឿង ការប្រមូលផ្តុំឯកសារច្បាប់ និងសាលក្រមនៅមានលក្ខណៈមិនទូលំទូលាយ និងមិនមានលក្ខណៈជាប្រព័ន្ធនៅឡើយ។

សិទ្ធិនេះនឹងមិនត្រូវបានគោរពនៅក្នុងប្រទេសជាសមាជិក ប្រសិនបើ៖ សេវាកម្មមានតម្លៃខ្ពស់ ការមិនយល់ដឹងពីច្បាប់។ ដើម្បីចៀសវាងបញ្ហាទាំងនេះ ប្រទេសមួយចំនួនដូចជាប្រទេសបារាំង បានបង្កើតនូវប្រព័ន្ធផ្តល់ជំនួយផ្នែកច្បាប់ និងផ្សព្វផ្សាយច្បាប់ដោយឥតគិតថ្លៃ។

រដ្ឋជាសមាជិកក៏ត្រូវបង្កើតស្ថាប័នដែលមានតួនាទីត្រួតពិនិត្យលើធម្មនុញ្ញភាពរបស់ច្បាប់ផងដែរ។

ជាឧទាហរណ៍ ក្នុងប្រទេសបារាំង ដើម្បីធានាឲ្យបាននូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងសំណុំរឿងរដ្ឋប្បវេណី រាល់ការចំណាយនានាគឺជាបន្ទុករបស់គូភាគី តែនៅក្នុងសំណុំរឿងព្រហ្មទណ្ឌគឺរដ្ឋជាអ្នករ៉ាប់រងរាល់ការចំណាយនៅក្នុងនីតិវិធីតុលាការ ហើយប្រជាពលរដ្ឋអាចបំពេញសំណុំបែបបទក្នុងការដាក់ពាក្យបណ្តឹងតាមរយៈប្រព័ន្ធអ៊ីនធើណិតដែលមានភាពងាយស្រួល ចំណាយថវិកា និងពេលវេលាតិច[3]។ ស្ថាប័នតុលាការនៅប្រទេសបារាំងចែកចេញជា២ប្រភេទ អាស្រ័យតាមប្រភេទនៃយុត្តាធិការដូចជា៖

១. យុត្តាធិការនៃតុលាការ ដែលមានការបែងចែកផ្សេងៗទៀត, តុលាការថ្នាក់ដំបូងទាក់ទងនឹងបណ្តឹងរដ្ឋប្បវេណីដែលមានទឹកប្រាក់ច្រើនជាង ១០,០០០ អឺរ៉ូ (មានចំនួន១៦១), តុលាការថ្នាក់ដំបូងទាក់ទងនឹងបណ្តឹងរដ្ឋប្បវេណីដែលមានទឹកប្រាក់តិចជាង១០,០០០អឺរ៉ូ (មានចំនួន៤) តុលាការពាណិជ្ជកម្ម (មានចំនួន១៣៤), តុលាការការងារទាក់ទងនឹងវិវាទសង្គមកិច្ច (មានចំនួន ៦), តុលាការប្រឹក្សាសវិវាទការងារ(មានចំនួន ២១០), តុលាការ សម្រាប់អនីតិជន (មានចំនួន ១៥៥), តុលាការឧក្រិដ្ឋ (មានចំនួន៣០៧), តុលាការរបបសន្តិសុខសង្គម (មានចំនួន ១១៥), តុលាការឧទ្ធរណ៍ (មានចំនួន៣៦) និងតុលាការជាន់ខ្ពស់ (មានចំនួន១) និង
២. យុត្តាធិការនៃតុលាការរដ្ឋបាល ដែលមានតុលាការរដ្ឋបាលថ្នាក់ដំបូង (មានចំនួន៤២), តុលាការរដ្ឋបាលថ្នាក់ឧទ្ធរណ៍ (មានចំនួន៨) និង ក្រុមប្រឹក្សារដ្ឋ (មានចំនួន១)។

## II. ការទទួលបានយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា

តាំងពីឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌[4] ដោយកំណត់នូវគោលការណ៍ណែនាំចំនួន៤៖ សិទ្ធិរបស់បុគ្គល លទ្ធិប្រជាធិបតេយ្យសេរី ការបែងចែកអំណាច និងនីតិរដ្ឋ។ នៅប្រទេសកម្ពុជា ការទទួលបានយុត្តិធម៌អាចធ្វើឡើងតាមរយៈការជំនុំជម្រះតាមផ្លូវតុលាការ (បណ្តឹងរដ្ឋប្បវេណី បណ្តឹងរដ្ឋបាល និងបណ្តឹងព្រហ្មទណ្ឌ) មជ្ឈត្តកម្ម

---

[3] http://vosdroits.service-public.fr/particuliers/F1816.xhtml

[4] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌, យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣។

(វិវាទការងារ និងពាណិជ្ជកម្ម) និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ទាក់ទងបណ្តឹងរដ្ឋប្បវេណី)។ យោងតាមការអះអាងរបស់នាយកប្រតិបត្តិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឲ្យដឹងថា គិតចាប់តាំងពីបង្កើតឡើងក្នុងឆ្នាំ២០០៣ រហូតដល់ខែមិថុនាឆ្នាំ២០១៤ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានដោះស្រាយវិវាទការងារស្ទើរតែទាំងអស់លើវិស័យកាត់ដេរមានចំនួនជាង១៨៥០ សំណុំរឿង[5]។ ពលរដ្ឋខ្មែរមានសិទ្ធិក្នុងការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានធានាដោយច្បាប់អន្តរជាតិ[6]ដែលបានផ្តល់សច្ចាប័នដោយមាត្រា៣១នៃរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា (ដូចជាសិទ្ធិទទួលបានសវនាការយុត្តិធម៌ និងជាសាធារណៈ ដោយសាលាជម្រះក្តីឯករាជ្យ សិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យារពេល សិទ្ធិយល់ពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី សិទ្ធិមានមេធាវី សិទ្ធិទទួលបានការសន្មត់ជាមុនថាគ្មានទោស សិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង សិទ្ធិប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) និងច្បាប់ជាតិ (ដូចជាការកំណត់អំពីសិទ្ធិរបស់ពលរដ្ឋ[7] ការធានាឯករាជ្យភាពរបស់តុលាការ[8] និងការកំណត់អំពីសិទ្ធិរបស់ជនសង្ស័យ[9])។ នៅក្នុងប្រព័ន្ធយុត្តិធម៌នៃប្រទេសកម្ពុជាក៏មានយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ក្រោមជាតិតាមរយៈការបង្កើតនូវមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង-ស្រុក-ខណ្ឌ[10] និងគណៈកម្មាធិការដោះស្រាយទំនាស់ ឃុំ-សង្កាត់[11] ។ ដើម្បីរក្សានូវទំនុកចិត្តពីប្រជាពលរដ្ឋមណ្ឌលសេវាកម្មយុត្តិធម៌ និងគណៈកម្មាធិការត្រូវធានានូវតម្លាភាព ការទទួលខុសត្រូវ និងការគ្រប់គ្រងល្អតាមរយៈការដោះស្រាយទំនាស់ដោយគោរពតាមក្រមសីលធម៌ដូចជាការរក្សាភាពសម្ងាត់ ការគោរពនូវសមធម៌ យុត្តិធម៌ និងសិទ្ធិមនុស្ស យេនឌ័រ និងចៀសវាងនូវការរើសអើង និងទំនាស់ផលប្រយោជន៍[12]។ មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង-ស្រុក-ខណ្ឌ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបណ្តុះបណ្តាល និងការប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សាឃុំអំពីបច្ចេកទេសក្នុងការសម្រុះសម្រួលវិវាទ និងផ្សព្វផ្សាយច្បាប់ សម្រុះសម្រួល និងផ្តល់សេវាពិគ្រោះយោបល់ច្បាប់ និងនីតិវិធីច្បាប់តាមប្រព័ន្ធតុលាការ ក្នុងករណីដែលវិវាទមិនអាចដោះស្រាយបាន ឬភាគីវិវាទមិនមានបំណងដោះស្រាយនៅថ្នាក់មូលដ្ឋាន[13]។ យន្តការនេះ

[5] http://www.khmer.rfi.fr/cambodia-interview-with-sok-lor-23-06-2014

[6] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, http://bit.ly/1gisTm1 ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, http://bit.ly/1j1mTd1 ។

[7] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា៣៨។

[8] ដូចឯកសារយោងលើ មាត្រា៥១-១២៨-១៣០ និង ១៣២។

[9] ក្រមនីតិវិធីព្រហ្មទណ្ឌអនុម័តនាឆ្នាំ២០០៧។ ក្រមព្រហ្មទណ្ឌដែលបានប្រកាសអោយប្រើក្នុងឆ្នាំ២០០៩ និង ចូលជាធរមាននាខែធ្នូ ឆ្នាំ២០១០

[10] មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង-ស្រុក-ខណ្ឌ បង្កើតដោយប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និង ក្រសួងមហាផ្ទៃ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌សាកល្បងនៅស្រុកចំនួន៤ដំបូង និង ប្រកាសចុះថ្ងៃទី១១ ខែកុម្ភៈឆ្នាំ២០០៨ សំរាប់ការបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌ចំនួន១៦បន្ថែម។

[11] គណៈកម្មាធិការដោះស្រាយទំនាស់ ឃុំ-សង្កាត់ បង្កើតដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ និង ប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និង ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា លេខ ៨៥/០៦ និង លេខ១៣/០៨ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។

[12] សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់, បោះពុម្ពដោយក្រសួងយុត្តិធម៌ឆ្នាំ២០១៣

[13] សៀវភៅណែនាំប្រតិបត្តិការសម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង-ស្រុក-ខណ្ឌ, បោះពុម្ពដោយក្រសួងយុត្តិធម៌ឆ្នាំ២០១៣, ទំព័រទី១។

មានទិសដៅដើម្បីកាត់បន្ថយនូវទំនាស់ សម្រាលបន្ទុកដល់ការងាររបស់តុលាការ ផ្សព្វផ្សាយ និងជំនួយពិគ្រោះផ្នែកច្បាប់ កាត់បន្ថយចំណាយ និងពេលវេលារបស់ប្រជាពលរដ្ឋ។

ដើម្បីធានាឲ្យមាននូវការទទួលបានយុត្តិធម៌ដែលមានឯករាជ្យភាព និងប្រសិទ្ធភាពតាមរយៈកំណែទម្រង់ប្រព័ន្ធតុលាការ ប្រទេសកម្ពុជាទើបតែបានអនុម័តច្បាប់ចំនួនបីទាក់ទងនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលច្បាប់និមួយៗមានគោលបំណងដូចខាងក្រោមនេះ៖

១. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមាន៦ជំពូក និង៣១មាត្រា មានគោលដៅបង្កើត និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងគោលបំណងជួយព្រះមហាក្សត្រដើម្បីធានាឯករាជនៃអំណាចតុលាការស្របតាមរដ្ឋធម្មនុញ្ញ និងមានវិសាលភាពត្រូវអនុវត្តទៅលើចៅក្រម និងព្រះរារអាជ្ញាទូទាំងប្រទេស។[14]

២. ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលមាន៦ជំពូក ស្មើនឹង១១១មាត្រា បានកំណត់ពីលក្ខន្តិកៈ និងគោលការណ៍ពាក់ព័ន្ធក្នុងគោលបំណងធានាឯករាជ្យនៃអំណាចតុលាការសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ក្នុងការរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។[15] និង

៣. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលមាន៨ជំពូក ស្មើនឹង៩១មាត្រា មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់អង្គតុលាការ អង្គការអយ្យការអមសាលាជម្រះក្តី សមត្ថកិច្ច និងរដ្ឋបាលតុលាការគ្រប់ជាន់ថ្នាក់ ក្នុងគោលបំណងផ្តល់យុត្តិធម៌និងបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ ធានារក្សាអនាគតិ ឯករាជ្យនៃអំណាចតុលាការ លើកកម្ពស់សិទ្ធពលរដ្ឋនិងសុវត្ថភាពសង្គម។[16]

ក្រៅពីច្បាប់សំខាន់ទាំងបីខាងលើ ថ្មីៗនេះសភាកម្ពុជាក៏បានអនុម័តច្បាប់ជាច្រើនផ្សេងទៀត ដើម្បីពង្រឹងនូវប្រព័ន្ធយុត្តិធម៌ជូនសង្គមនិងប្រជាជនកម្ពុជា ដែលច្បាប់ទាំងនោះមានដូចជា៖

1. ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកយុត្តិធម៌ក្នុងវិស័យរដ្ឋប្បវេណីរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម។ ការជួយគ្នានេះគឺផ្តោតទៅលើ ការប្រមូលនិងការបញ្ជូនភស្តុតាង ការកោះហៅសាក្សី និងអ្នកជំនាញ ការផ្លាស់ប្តូព័ត៌មាន ការទទួលស្គាល់ និងការអនុញ្ញាតឲ្យអនុវត្តសាលក្រម សាលដីកា សេចក្តីសម្រេចរបស់តុលាការ និងរបស់មជ្ឍត្តករ និងទិដ្ឋភាពដ៏ទៃទៀតសម្រាប់រឿងក្តីរដ្ឋបវេណី។[17]

---

[14] ច្បាប់នេះត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧

15 មាត្រា១និងមាត្រា២ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥

16 មាត្រា១និងមាត្រា២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦

[17] មាត្រា១ដល់មាត្រា៥ នៃកិច្ចព្រមព្រៀងស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកយុត្តិធម៌ក្នុងវិស័យរដ្ឋប្បវេណីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាមដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៨

2. ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាការព្រមព្រៀងធ្វើបត្យាប័ននូវជនដែលអាចធ្វើបត្យាប័នបានដូចមានចែងនៅក្នុងមាត្រា២នៃសន្ធិសញ្ញានេះ ដើម្បីធ្វើការចោទប្រកាន់ ជំនុំជម្រះ ឬអនុវត្តទោសចំពោះបទល្មើស តាមការស្នើសុំរបស់រដ្ឋភាគីនៅក្នុងសន្ធិសញ្ញានេះ។[18]
3. ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ គឺជាច្បាប់ដែលតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជា បន្តនូវរាល់នីតិវិធីដើម្បីអនុវត្តយុទ្ធសាស្ត្រនេះឲ្យបានសម្រេច ដែលនៅក្នុងយុទ្ធសាស្ត្រនេះក៏បានកំណត់នូវអាទិភាពក្នុងការកែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ព្រមទាំងមានគម្រោងបង្កើនថវិកាបន្ថែមរៀងរាល់ឆ្នាំដល់ក្រសួងយុត្តិធម៌ដើម្បីលើកកម្ពស់យុត្តិធម៌នៅក្នុងប្រទេសកម្ពុជាផងដែរ។[19] និង
4. ច្បាប់ស្តីពី ការធានារ៉ាប់រងគឺជាច្បាប់ដែលគ្របដណ្តប់លើការធានារ៉ាប់រងអាយុជីវិត និងការធានារ៉ាប់រងខ្នាតតូច ដែលនេះក៏បានបើកចំហរនូវភាពបទបែនសម្រាប់បញ្ញត្តករតាមរយៈការចេញអនុក្រឹត្យ ឬប្រកាសបន្ថែមលើច្បាប់ដែលមានស្រាប់ដើម្បីធ្វើអន្តរាគមន៍ដោយយុត្តិធម៌នៅពេលឧស្សាហកម្មណាមួយមានស្ថានភាពមិនល្អ។

ទាក់ទងនឹងការបណ្តុះបណ្តាលប្រទេសកម្ពុជាមានសាលាភូមិន្ទវិជ្ជាជីវៈតុលាការដែលមានសាលាបួនដើម្បីធ្វើការបណ្តុះបណ្តាល ចៅក្រម ក្រឡាបញ្ជី សារការី និងអាជ្ញាសាលា។ សាលាទាំងនេះឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌នាឆ្នាំ២០១៣។ មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវីត្រូវបានបង្កើតនាឆ្នាំ២០០១។

ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏បានផ្តល់នូវកេរ្តិ៍តំណែលមិនត្រឹមតែនៅក្នុងស្ថាប័នតុលាការជាតិប៉ុណ្ណោះទេ តែក៏ជាស្ថាប័នតុលាការអន្តរជាតិគំរូផងដែរ។ តុលាការកូនកាត់មួយនេះអាចនឹងផ្តល់នូវផលវិជ្ជមានដល់កំណែទម្រង់ច្បាប់ និង តុលាការ ដូចជាការបង្កើតប្រព័ន្ធបញ្ចូលទិន្ន័យសម្រាប់ឯកសារច្បាប់ជាតិ និងអន្តរជាតិ សំណុំរឿង និងសាលក្រមគ្រប់ទម្រង់ (អត្ថបទ សម្លេង រូបភាព និងវីដេអូ) នៅក្នុងបណ្ណាល័យអេឡិចត្រូនិច[20] ដោយមិនយកកម្រៃ និងដោយសេរី ដើម្បីសម្រួលដល់ការពិភាក្សា និង ស្រាវជ្រាវដល់និស្សិត អ្នកអនុវត្តច្បាប់ និងអ្នកស្រាវជ្រាវច្បាប់ទាំងជាតិ និងអន្តរជាតិក្នុងកម្មវិធីពង្រឹងសមត្ថភាពវិជ្ជាជីវៈ[21]។ ជាក់ស្តែង តុលាការឧទ្ធរណ៍បានចាប់ផ្តើមធ្វើការសាកល្បងនូវការចុះបញ្ជីសំណុំរឿង ឯកសារច្បាប់ និងសាលក្រមតាមរយៈការបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

---

18 មាត្រា១ដល់មាត្រា៩នៃច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០២០

19 មាត្រា៩ និងមាត្រា១០២នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៩

20 vt.eccc.gov.kh

21 ទស្សនៈវិស័យលើកេរ្តិ៍តំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, សន្និសិទនាថ្ងៃទី១៣-១៤ ខែកញ្ញា ឆ្នាំ២០១២។

មានអង្គការមិនមែនរដ្ឋាភិបាលប្រហែល១៩[22] បានផ្តល់ជំនួយដោយឥតគិតថ្លៃទាក់ទងនឹងការពិគ្រោះយោបល់ផ្នែកច្បាប់ និងផ្សព្វផ្សាយច្បាប់ ដើម្បីបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ ៕

[22] http://www.licadho-cambodia.org/; http://cambodia.ohchr.org/klc_pages/klc_english.htm; http://lac.org.kh/; http://tmp.sithi.org/; http://www.ccc-cambodia.org/; http://www.adhoc-cambodia.org/; http://www.humanrights.asia/; http://www.cdpcambodia.org/; www.cdri.org.kh/; www.cwcc.org.kh/; www.cwsglobal.org/; www.comfrel.org/eng/; www.clec.org.kh/; ngocrc.org/ ; www.cosecam.org/; www.ecpat.net/; www.gadc.org.kh/; www.lscw.org/; www.nyemo.com/; www.genderit.org/content/open-forum-cambodia; www.opensocietyfoundations.org/;

# គន្ថនិទ្ទេស

- សន្និសីទលើកទី៣នៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃប្រទេសនិយាយភាសាបារាំងរៀបចំឡើងដោយភ្នាក់ងារអន្តររដ្ឋាភិបាលនៃប្រទេសនិយាយភាសាបារាំង នៅទីក្រុងCaire នាខែវិច្ឆិកា ឆ្នាំ១៩៩៥
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌអនុម័តនាឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌដែលបានប្រកាសអោយប្រើក្នុងឆ្នាំ២០០៩ និងចូលជាធរមាននាខែធ្នូ ឆ្នាំ២០១០
- សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់, បោះពុម្ពដោយក្រសួងយុត្តិធម៌ឆ្នាំ២០១៣
- សៀវភៅណែនាំប្រតិបត្តិការសម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង-ស្រុក-ខណ្ឌ, បោះពុម្ពដោយក្រសួងយុត្តិធម៌ឆ្នាំ២០១៣
- សៀវភៅណែនាំការសម្រុះសម្រួល, បោះពុម្ពដោយក្រសួងយុត្តិធម៌ឆ្នាំ២០១៣